សលាកប័ត្រព័ត៌មាន NEWSLETTER
លេខៈ ៤២ ខែមីនា-មេសា ឆ្នាំ២០០៩
Issue: 42 March-April 2009

# ឃ្លាំមើល សាលាក្តីខ្មែរក្រហម
# KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

## អង្គជំនុំជម្រះសាលាដំបូងបើកការជំនុំជម្រះ សំណុំរឿងអតីតប្រធានគុកទួលស្លែង

### ECCC's Trial Chamber Hears the Case of Former Chief Tuol Sleng Torture Center

ចាប់តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ មក អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានឈ្មោះក្រៅផ្លូវការថា *"សាលាក្តីខ្មែរក្រហម"* បានបើកសវនាការ អង្គសេចក្តីជំនុំជម្រះទៅលើសំណុំរឿងនៃអតីតប្រធានមន្ទីរស-២១ (មន្ទីរសន្តិបាល) ឬហៅថា គុកទួលស្លែង ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**" ដោយមាន ការចូលរួម ពីសំណាក់ជនរងគ្រោះរាប់រយនាក់ក្រុមគ្រួសារជនត្រូវចោទសាធារណជនជាតិ និងអន្តរជាតិផងដែរ។



*វត្តមានរបស់ ឌុច នៅក្នុងសាលសវនាការសាលាដំបូងថ្ងៃជំនុំជម្រះ*

ការទន្ទឹងរង់ចាំឱ្យមានសវនាការកាត់សេចក្តីមួយដោយត្រឹមត្រូវ និងយុត្តិធម៌ ជាពិសេសតាមរយៈសាលាក្តីកូនកាត់មួយនេះ គឺពិតជាបានចំណាយពេលដ៏យូរ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរលំទៅនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ការពិតការចរចា ឱ្យមានការបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកើតចេញពីកិច្ចចចារអស់រយៈពេលដ៏យូរផងដែរ រវាងភាគីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីធ្វើការកាត់សេចក្តីទៅក្រុមមនុស្សពីរជំពូក គឺៈ ***មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម*** ដែលបានកើតឡើងនៅក្រោមរបបដឹកនាំដោយ **ប៉ុល ពត** ពីចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ព្រឹត្តិការណ៍ នៃការកាត់សេចក្តីលើកនេះ គឺជាក្តីសង្ឃឹមរបស់ជនរងគ្រោះកម្ពុជា ចំពោះការជឿនលឿនទៅមុខរបស់សាលាក្តីខ្មែរក្រហមនេះ ជាពិសេស បន្ទាប់ពីមានការបើកសវនាការបឋមទៅលើសំណុំរឿងរបស់អតីតប្រធានមន្ទីរស-២១ នេះ កាលពីពាក់កណ្តាល ខែកុម្ភៈ ឆ្នាំ២០០៩ កន្លងមក។ នេះ គឺជាការកាត់សេចក្តីជាលើកដំបូងគេ ទៅលើអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា ដែលបានកើតឡើងនៅក្នុង **មន្ទីរស-២១, គុកព្រៃស និងវាលពិឃាតជើងឯក** នៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ជនជាប់ចោទឈ្មោះ **ឌុច** រូបនេះ ខណៈពេលដែលអតីតមេដឹកនាំចំនួន៤រូបទៀត ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងក្នុងនោះមាន **លោក នួន ជា លោក អៀង សារី លោកស្រី អៀង ធីរិទ្ធិ និងលោក ខៀវ សំផន** ដែលនឹងត្រូវកាត់សេចក្តីនៅពេលខាងមុខទៀត។

សវនាការអង្គជំនុំជម្រះសាលាដំបូង ដែលបានប្រព្រឹត្តឡើង នៅពេលនោះ មានចៅក្រមជំនុំជម្រះចំនួនប្រាំរូប គឺចៅក្រមខ្មែរបីរូប និងចៅក្រមអន្តរជាតិពីររូប ដែលដឹកនាំដោយលោកចៅក្រម **និល ណុល** ជាប្រធាន។ នៅចំពោះមុខអង្គចៅក្រម ជនជាប់ចោទ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**" ដែលជាឈ្មោះបដិវត្តន៍របស់គាត់ ត្រូវបានកោះហៅឱ្យមកអង្គុយនៅក្នុងរង្វង់ក្រចកសេះ ក្រោមក្រសែភ្នែកតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកចូលរួមទាំងអស់ ដែលមានវត្តមាននៅក្នុងសាលសវនាការដែលមានប្រមាណជាង ៥០០ នាក់។ នៅក្នុងបន្ទប់សវនាការពេលនោះផងដែរ ក៏មានវត្តមានសហព្រះរាជអាជ្ញា**លោកស្រី ជា លាង និងលោក រ៉ូប៊ឺត ពើទីត** និងសហព្រះរាជអាជ្ញារង, សហមេធាវីការពារជនជាប់ចោទ គឺលោក **ការ សាវុត្ថ និងលោក ហ្វ្រង់ស្វ័ររូហ៊ី** និងមេធាវីការពារដើមបណ្តឹងរដ្ឋប្ប

អាសយដ្ឋាន : ផ្ទះលេខ៩Eo ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន។ ទូរស័ព្ទ/ទូរសារៈ (០២៣) ៣០១ ៤១៥ អ៊ីមែលៈ chrac@forum.org.kh គេហទំព័រៈ www.chrac.org

វេណី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបផងដែរ។

នៅមុនពេលដំណើរកិច្ចសួរដេញដោល ក្រឡាបញ្ជីអានសាលដីកាបញ្ជូនរឿងឱ្យជំនុំជម្រះ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត គឺ លោក **យូ ប៊ុនឡេង** និងលោក **ម៉ាកសែល ឡឺម៉ុងដ៏** ដែលមានអត្ថន័យសំខាន់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិ និងឧក្រិដ្ឋកម្មទាំងឡាយ ដែលបានកើតឡើងនៅក្នុង មន្ទីរស-២១ គុកព្រៃស និងទីពិឃាតជើងឯក ដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ជនជាប់ចោទឈ្មោះ **ឌុច** នេះ។

យោងតាមសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជូនអង្គសវនាការ ដែលបានលើកឡើងដោយ **លោកស្រី ជា លាង និងលោក រ៉ូប៊ឺត ពើទីត** កត់សំគាល់ថា ជនជាប់ចោទរូបនេះត្រូវតែទទួលខុសត្រូវ ចំពោះអំពើដែលបានកើតឡើង ព្រោះថាក្នុងឋានៈរបស់ខ្លួន ដែលជាប្រធានមន្ទីរស-២១ ឌុច បានចូលរួមរៀបចំផែនការញុះញង់ លើកទឹកចិត្ត និងជួយជំរុញឱ្យកើតមានអំពើឧក្រិដ្ឋផ្សេងៗជាច្រើន។ អំពើទាំងនោះ រួមមាន ដូចជាៈ ការដកហូតនូវសិទ្ធិជាមូលដ្ឋានរបស់មនុស្ស, ការឃុំឃាំង, ការធ្វើទារុណកម្ម, ការសំលាប់រង្គាល, ការបង្ខំឱ្យធ្វើការដោយបង្ខំ, ការរំលោភបំពានផ្លូវភេទ, ការធ្វើទុក្ខបុកម្នេញ, និងអំពើអមនុស្សធម៌ផ្សេងៗ ដែលជាការរំលោភបំពានទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ជាលទ្ធផលនៃការប្រព្រឹត្តទាំងនេះ បានបណ្តាលឱ្យអ្នកទោស និងជនស៊ីវិល បានស្លាប់បាត់បង់ជីវិតអស់ជាង ១២,៣៨០ នាក់ (បញ្ជីសំរង់រួម) ដែលរួមមាន បុរស ស្ត្រី ចាស់ក្មេង ជនស៊ីវិល ឈ្លើយសឹកវៀតណាម កម្មាភិបាលខ្មែរក្រហម មន្ត្រីរាជការ នៃរបបលន់ ណុល អ្នកថ្មី និងជនបរទេសជាដើម។

យោងតាមការបញ្ជាក់នៅក្នុងដីកានេះ គឺថា **មន្ទីរស-២១** គឺជាទីស្នាក់ការនៃសាខាពិសេសរបស់នគរបាលសន្តិបាល (សន្តិបាល) នៃបក្សកុម្មុយនីស្តកម្ពុជា។ មន្ទីរស-២១ ជាមន្ទីរសន្តិសុខតែមួយគត់ ក្នុងចំណោមមន្ទីរសន្តិសុខនានា ដោយសារតែមានទំនាក់ទំនងផ្ទាល់ ជាមួយនឹងគណៈកម្មាធិការមជ្ឈិមបក្ស និងមានតួនាទីក្នុងការឃុំខ្លួន និងការសំលាប់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា។

ដូចនេះ តាមរយៈអំពើ និងការទទួលខុសត្រូវរបស់ជនជាប់ចោទរូបនេះនៅក្នុងមន្ទីរស-២១ នេះហើយ ទើបបានជាគាត់ត្រូវបានសហព្រះរាជអាជ្ញាចោទប្រកាន់ និងបានត្រូវសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេត និងបានសំរេចចោទប្រកាន់ជននេះនូវបទល្មើសសំខាន់ៗចំនួន៤ប្រភេទដូចជា នៅក្រោមច្បាប់អន្តរជាតិៈ **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, អំពើបំពារបំពាននឹងអនុសញ្ញាក្រុងហ្សឺណែវ (ឧក្រិដ្ឋកម្មសង្គ្រាម)** និង នៅក្រោមច្បាប់ជាតិរួមមានៈ **អំពើមនុស្សឃាត និងអំពើទារុណកម្ម**។

នៅក្នុងសវនាការកាត់សេចក្តីរយៈពេល៦ថ្ងៃ ដំបូងនេះ មានការលើកឡើងនូវបញ្ហាសំខាន់ៗមួយចំនួន គិតមកត្រឹមថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០០៩ រួមមាន ដូចជាៈ

### ១- ឌុច បានឆ្លើយសារភាពទទួលកំហុស និងសុំអភ័យទោសៈ

នៅសវនាការថ្ងៃទី៣១ ខែមេសា ឆ្នាំ២០០៩ (ថ្ងៃទីពីរ) **ឌុច** ត្រូវអង្គចៅក្រមអនុញ្ញាតឱ្យឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា គាត់បានទទួលស្គាល់ចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជា និងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ **ឌុច** បាននិយាយថាៈ "*ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាមានតួនាទីទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តនៅជំនាន់នោះ។ ខ្ញុំសូមសំដែងនូវវិប្បដិសារីសោកស្តាយយ៉ាងឈឺចាប់បំផុត ចំពោះឧក្រិដ្ឋកម្មគ្រប់យ៉ាង ដែលបក្សកុម្មុយនីស្តប្រព្រឹត្ត ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩....*"។ លើសពីនេះទៅទៀត ជនជាប់ចោទរូបនេះ ក៏បានទទួលស្គាល់នូវឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងមន្ទីរស-២១ ទៅតាមច្បាប់ផងដែរ ព្រមទាំងបានសុំទោសទៅដល់ក្រុមគ្រួសារជនរងគ្រោះ ដែលបាននៅរស់រានមានជីវិតយ៉ាងអាណោចអាធ័មនៅមន្ទីរស-២១ នោះផងដែរ។

បើទោះបីជា **ឌុច** បានឆ្លើយសារភាពនូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរស-២១, ម-២៤ (គុកព្រៃស) និងជើងឯក ក៏ដោយ ក៏គាត់បានលើកឡើងថាគាត់បានធ្វើទៅតាមបញ្ជារបស់ **សុន សេន** (អតីតឧបនាយក រដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងបច្ចុប្បន្ន គាត់បានស្លាប់ហើយ) និងបងធំទី២ **នួន ជា** ដែរ។

### ២- មេធាវីការពារក្តីឌុចលើកឡើងនូវការឃុំខ្លួនខុសច្បាប់ៈ

**លោក ហ្វ្រង់ស្វ័រ រូហ៏** ដែលជាមេធាវីអន្តរជាតិជនជាតិបារាំង ការពារជនជាប់ចោទ ឌុច ត្រូវបានអង្គចៅក្រមអនុញ្ញាតឱ្យលើកឡើងនូវបញ្ហាឃុំខ្លួន ឌុច (នៅមុនពេលសវនាការ) អស់

រយៈពេលជិត ១០ឆ្នាំ នៅឯតុលាការយោធា ដោយមិនមានការកាត់ទោស។



*មេធាវី ហ្វ្រង់ស្វ័រ រូហ៊ី(ខាងឆ្វេង) និងមេធាវី ការ សាវុត្ថ (ខាងស្ដាំ)*

លោក **រូហ៊ី** បានគូសបញ្ជាក់ថា ការឃុំខ្លួនពន្យារពេលដ៏យូរនេះ គឺជាការរំលោភទាំងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ ការលើកឡើងរបស់មេធាវីការពារក្ដីរូប នេះគឺ ដើម្បីបង្ហាញដល់ការគិតគូរពិចារណារបស់អង្គចៅក្រមក្នុងសំរាលទោស និងថាកូនក្ដីរបស់គាត់គួរត្រូវបានអាជ្ញាធរកម្ពុជាផ្ដល់សំណងជំងឺចិត្ត ចំពោះការឃុំខ្លួនខុសច្បាប់នេះ។

ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា លោកស្រី **ជា លាង** បានឆ្លើយតបទៅនឹងការស្នើសុំឱ្យមានការគិតគូរចំពោះការឃុំខ្លួន **ឌុច** នៅមុនពេលបញ្ជូនមកដាក់ឱ្យស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះថា ការឃុំខ្លួននេះ មិនជាប់ពាក់ព័ន្ធគ្នាទេ ពីព្រោះថា ការឃុំខ្លួនពីមុននេះ (កាលពីឆ្នាំ១៩៩៩)គឺ ធ្វើឡើងក្រោមយុត្តាធិការរបស់តុលាការយោធា។

### ៣- ឌុច ឆ្លើយអំពីទំនាក់ទំនងអាមេរិក ដែលនាំឱ្យកើតរបបខ្មែរក្រហមៈ

នៅក្នុងសវនាការថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ (ថ្ងៃទីបី) **កាំង ហ្គេកអ៊ាវ** បាននិយាយថា ក្រុមខ្មែរក្រហមមិនអាចងើបរួចទេកាលពីឆ្នាំ១៩៧០ ប្រសិនបើមិនមានការគាំទ្រពីអតីតប្រធានាធិបតីអាមេរិក លោក **រីឆាត និចសុន** (Richard Nixon) និងអតីតរដ្ឋមន្ត្រីការបរទេស **ហិនរី ឃីស៊ីងហ្គើរ** (Henry Kissinger) ដែលបានគាំទ្រឱ្យមានរដ្ឋប្រហារនៅកម្ពុជា។ **ឌុច** ក៏បានបន្ថែមទៀតថា គាត់មើលឃើញថា អាមេរិក គឺជាផ្នែកមួយដែលនាំឱ្យមានរបបខ្មែរក្រហម ទទួលបានជ័យជំនះ ហើយកាន់កាប់ ប្រទេសកម្ពុជា ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

### ៤- ការចូលរួមរបស់ជនរងគ្រោះ និងសាកសួរសាក្សីៈ

***ការចូលរួមរបស់ជនរងគ្រោះជាដើមបណ្ដឹងរដ្ឋប្បវេណីៈ*** នៅពេលបើកសវនាការពីរថ្ងៃដំបូង មានវត្តមានរបស់ដើមបណ្ដឹង ចំនួន៩៣នាក់ ដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿងរបស់ឌុច នេះផងដែរ។ នៅក្នុងបន្ទប់សវនាការគេក៏ឃើញមានវត្តមានដើមបណ្ដឹងរដ្ឋប្បវេណីអង្គុយចំនួន១០នាក់ ដោយផ្លាស់ប្ដូរគ្នាចូលរួមស្ដាប់ ពីព្រោះកន្លែងអង្គុយផ្សេងទៀតទុកសំរាប់មេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

***ការឆ្លើយបំភ្លឺរបស់សាក្សី និងអ្នកជំនាញៈ***

ក្រោយពីការសាកសួរការឆ្លើយដោះសាររបស់ជនជាប់ចោទ ឌុច រួចមក អង្គចៅក្រមបានអនុញ្ញាតឱ្យមានការចូលរួមផ្ដល់សក្ខីកម្មដោយសាក្សីមួយចំនួនក្នុងនោះក៏មានលោក **ហ្វ្រង់ស្វ័រ ប៊ីស្សូ** ជាដែលប្រវត្តិវិទូជនជាតិបារាំង ដែលត្រូវឃុំខ្លួននៅ ម-១៣ (ជាគុកដែលស្ថិតនៅអមលាំងខេត្តកំពង់ស្ពឺ) ដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឌុចផងដែរនៅឆ្នាំ១៩៧១។ លោក **ប៊ីស្សូ** បានគូសបញ្ជាក់ថា លោកត្រូវបានចាប់ឃុំខ្លួននៅ ម-១៣ និងត្រូវបានដោះលែងវិញដោយមិនបានទទួលការធ្វើទារុណកម្មជំនុំអ្វីឡើយ។ គាត់ជាសាក្សីដោះបន្ទុកម្នាក់របស់ **ឌុច** នៅក្នុងសំណុំរឿងនេះ ។

គួរបញ្ជាក់ថា តាមការគ្រោងទុក សវនាការកាត់សេចក្ដីអតីតប្រធានមន្ទីស-២១ នេះ នឹងអាចបញ្ចប់នៅអំឡុងដើមខែកក្កដា ឆ្នាំ២០០៩ ខាងមុខនេះ និងដឹងថាតើឌុច ត្រូវដោះលែង ឬយ៉ាងណា។

## មន្ត្រីអង្គការសហប្រជាជាតិជួបពិភាក្សាបញ្ហាពុករលួយនៅសាលាក្ដីខ្មែរក្រហម

## Senior UN Official Meets to Discuss Corruption Allegations at the Khmer Rouge Tribunal

នៅស្របពេលដែលអង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្ដើមការបើកសវនាការអង្គសេចក្ដី ទៅលើសំណុំរឿងអតីតប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ចាប់ពីចុងខែមីនានេះមកដំណើរការស្វែងរកយុត្តិធមិនៅកម្ពុជា ត្រូវបានសាធារណៈមតិជាតិនិងអន្តរជាតិជាពិសេសជនរងគ្រោះកម្ពុជាអបអរសាទរជាខ្លាំងប្រកបដោយក្ដីសង្ឃឹម។ ប៉ុន្តែទន្ទឹមនឹងនេះ ក៏នៅមានបញ្ហាចោទមួយចំនួនដែលកំពុងតែស្ថិតនៅក្នុងភាពព្រួយបារម្ភផងដែររាប់បញ្ចូលទាំង *បញ្ហាកង្វះថវិកា បញ្ហាចោទប្រកាន់អំពីអំពើពុករលួយ និងបញ្ហាជ្រៀត*

*ជ្រែកនយោបាយ* ពីអំណាចនីតិប្រតិបត្តិទៅលើឯករាជ្យភាពរបស់សាលាក្តីខ្មែរក្រហម ដែលកំពុងតែដំណើរការនេះ ជាពិសេសទាក់ទិននឹងថាតើ សាលាក្តីនេះអាចស៊ើបអង្កេត និងចោទប្រកាន់ជនសង្ស័យថ្មីបន្ថែមទៀត ឬក៏អត់នោះ។

ហេតុដូចនេះ ហើយបានជា លោក **ភីធើ ថាក់ស្វ ជេនសុន** (Peter Takoe Jenson) ឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិសំរាប់កិច្ចការច្បាប់ពាក់ព័ន្ធសាលាក្តីខ្មែរក្រហម បានអញ្ជើញមកប្រទេសកម្ពុជា ដើម្បីជួបពិភាក្សាជាមួយនឹងឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រីតំណាងរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី៦ ដល់ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០០៩ ថ្មីៗនេះ។ នេះ គឺកិច្ចចរចាលើកទី៣ ហើយ ទាក់ទងនឹងបញ្ហាពង្រឹងការគ្រប់គ្រងដំណើរការប្រព្រឹត្តទៅរបស់ការិយាល័យរដ្ឋបាលរបស់សាលាក្តីកូនកាត់នេះ ក៏ដូចជាការពង្រឹងធនធានមនុស្សផងដែរ ជាពិសេស គឺដើម្បីរៀបចំយន្តការដោះស្រាយបញ្ហា ចោទប្រកាន់អំពីអំពើពុករលួយនៅខាងភាគីកម្ពុជា នៃសាលាក្តីនេះ។

យោងទៅតាមសេចក្តីថ្លែងការណ៍ របស់អង្គការសហប្រជាជាតិស្តីពីលទ្ធផលនៃជំនួបរវាងថ្នាក់ដឹកនាំទាំងពីរភាគីនេះ បានគូសបញ្ជាក់ថា: មានការវិវត្តន៍ជាវិជ្ជមានមួយចំនួន ក៏ប៉ុន្តែបញ្ហាយន្តការដោះស្រាយនូវបណ្តឹងចោទប្រកាន់អំពីអំពើពុករលួយ នៅមិនទាន់មានការឯកភាពគ្នាទាំងស្រុងនៅឡើយ ដោយខាងភាគីអង្គការសហប្រជាជាតិនៅតែទទូចសូមមានយន្តការដោះស្រាយអំពីបញ្ហាពុករលួយនេះឱ្យមានប្រសិទ្ធភាព។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ លោកក៏បានទុកនូវសំណើមួយរបស់លោក ដើម្បីជូនលោកឧបនាយករដ្ឋមន្ត្រីពិចារណាបន្ថែមទៀតផងដែរ។

ចំពោះខាងភាគីកម្ពុជា ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សានោះក៏ បានមានប្រសាសន៍ថា កិច្ចពិភាក្សាបានជោគជ័យ បើទោះជាមិនទាន់ឯកភាពគ្នាលើចំណុចមួយចំនួនក៏ដោយ។

ការពិតបណ្តឹងទាក់ទិននឹងអំពើពុករលួយនេះ បានលេចលឺតាំងពីឆ្នាំកន្លងទៅមកម្ល៉េះ ប៉ុន្តែគេនៅមិនទាន់បានដឹងនូវចំណាត់ការដោយខាងភាគីកម្ពុជា ដើម្បីបើកការស៊ើបអង្កេតទៅលើករណីនៅឡើយមកដល់ពេលនេះ។ បញ្ហានេះមិនគ្រាន់តែជាអ្វីដែលបានលេចលឺប៉ុណ្ណោះទេ ប៉ុន្តែក្លាយទៅជាកម្មវត្ថុនៃបណ្តឹង ដែលបានស្នើសុំដោយភាគីមេធាវីការពារក្តីប្តឹងសូមឱ្យបើកការស៊ើបអង្កេតទៀតផង។ ជាក់ស្តែង ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ប៉ុន្តែបន្ទាប់មកត្រូវបានបដិសេធចោល។ កាលពីក្នុងសវនាការបណ្តឹងស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទ **អៀង សារី** និង **ខៀវ សំផន** សហមេធាវីការពារក្តីក៏បានលើកឡើងនូវបញ្ហាចោទប្រកាន់ពុករលួយនេះដែរ តែត្រូវបានចៅក្រមអង្គបុរេជំនុំជម្រះក៏ដូចជាសហចៅក្រមស៊ើបអង្កេតក៏បានបដិសេធដែរ ដោយលើកឡើងថា មិនមានយុត្តាធិការទៅលើបញ្ហានេះឡើយ ព្រោះថា នេះគឺជាកិច្ចការ និងជាសមត្ថកិច្ចរបស់អាជ្ញាធរកម្ពុជា និងអង្គការសហប្រជាជាតិ។

ទាក់ទិននឹងបញ្ហានេះដែរ អង្គការសង្គមស៊ីវិលក៏បានសំដែងនូវការព្រួយបារម្ភដែរ ពីព្រោះថា បញ្ហាពុករលួយដែលត្រូវបានចោទប្រកាន់ និងបញ្ហាឯករាជ្យភាពរបស់សាលាក្តីខ្មែរក្រហម ត្រូវតែដោះស្រាយឱ្យបានឆាប់រហ័ស ដើម្បីបង្កើនទំនុកចិត្ត និងបង្កលក្ខណៈឱ្យការកាត់ក្តីប្រកបដោយយុត្តិធម៌ទៅមុខដោយរលូនតទៅមុនទៀត។

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ*
*មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី(NED) និង ឌី.អ៊ី.ឌី(DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: អ៊ិន.អ៊ី.ឌី និង ឌី.អ៊ី.ឌី**

**ព័ត៌មានសំខាន់:**

➤ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ចូលរួមដាក់ពាក្យបណ្តឹង**ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្តីខ្មែរក្រហម**

**សូមទាក់ទង:**

- **សមាគមសិទ្ធិមនុស្សអាដហុក (ADHOC)**
  លេខទូរស័ព្ទ: ០២៣ ៩៩០ ៥៤៤
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID)
  លេខទូរស័ព្ទ: ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)
  លេខទូរស័ព្ទ: ០២៣ ៣៦៤ ៧៣៥
- អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRO)
  លេខទូរស័ព្ទ: ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១

➤ ស្តាប់កម្មវិធីឃ្លាំមើលសាលាក្តីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញតាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។
➤ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ **www.krtrial.info**